ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ: ១១៤/៧៤ អជណ.អក.ទប

# សេចក្ដីជូនដំណឹង

## ស្ដីពី ការជ្រើសរើសបុគ្គលិក ជាបន្ទាន់

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើស **បុគ្គលិក** សម្រាប់ **ផ្នែកសិក្សាគម្រោងបណ្ដាញ, ផ្នែកសិក្សាគម្រោងផលប៉ះពាល់ប្រព័ន្ធបណ្ដាញ, ផ្នែកគំនូសប្លង់បច្ចេកទេស** និង **ផ្នែកតាមដានការអនុវត្តគម្រោង** សរុបចំនួន **១៥ រូប** ជាបន្ទាន់ ដើម្បីចូលបម្រើការងារ នៅការិយាល័យបច្ចេកទេសចែកចាយ នៃនាយកដ្ឋានអាជីវកម្មចែកចាយ ដូចខាងក្រោម :

*- **លក្ខណៈសម្បត្តិបេក្ខជន** :

- បេក្ខជនទាំង ០២ ភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្ដល់ជូន : បៀវត្សរ៍សុទ្ធ E.I.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រវិស្វករអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ AutoCAD, Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន ។

*- **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

- ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន ០១ ច្បាប់
- កិច្ចសន្យា សម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ ចំនួន ០១ ច្បាប់
- សលាកប័ត្របេក្ខជន ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ មានបញ្ជាក់ពីអាជ្ញាធរដែនដី ចំនួន ០១ ច្បាប់
- តារាងពិន្ទុ (TRANSCRIPT) ចំនួន ០១ ច្បាប់

*- **ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធ នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម ។**

*- **ទីកន្លែងទទួលពាក្យ** : **នៅអគារ B ជាន់ទី១ ការិយាល័យបុគ្គលិក នៃអគ្គិសនីកម្ពុជា**
ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០ ។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្ដាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៦

ជ. **ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**អគ្គនាយករង**

អេង_គន្ធា

**បញ្ជាក់**

- សេចក្ដីជូនដំណឹងនេះ ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់ អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ "។